# សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានបូកបីលើកទី១៣

(13TH ALMM+3)

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤, ប្រទេសសិង្ហបុរី

---

១. កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានបូកបីលើកទី១៣ (13th ALMM+3) បានប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី។ កិច្ចប្រជុំនេះ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត Tan See Leng រដ្ឋមន្ត្រីក្រសួងហត្ថពលកម្ម នៃប្រទេសសិង្ហបុរី និងមានការចូលរួមពីតំណាងប្រទេសសមាជិកអាស៊ាន ចិន ជប៉ុន និងសាធារណៈរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) អគ្គលេខាធិការអាស៊ាន និងគណៈប្រតិភូអមដំណើររដ្ឋមន្ត្រីតាមប្រទេស។ តំណាងប្រទេសទីម័រខាងកើតបានចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍។

**ការផ្លាស់ប្តូរទស្សនៈ ស្តីពីមូលបទ "ការពង្រឹងភាពធន់ និងការលើកកម្ពស់នវានុវត្តន៍"**

២. យើងបានទទួលស្គាល់ថា ចាប់តាំងពីការសម្ពោធ ALMM នៅទីក្រុងហ្សាការតាក្នុងខែមេសា ឆ្នាំ១៩៧៥ ស្ថានភាពក្នុងតំបន់បានប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការកែលម្អល័ក្ខខ័ណ្ឌការងារ ស្តង់ដាការងារ និងការប្រកួតប្រជែងរបស់កម្មករនិយោជិតទាំងអស់នៅក្នុងតំបន់។ តាមរយៈកិច្ចសហប្រតិបត្តិការដ៏យូរអង្វែង ក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ស្របតាមចក្ខុវិស័យ នៃសហគមន៍អាស៊ានប្រកបដោយសន្តិភាព វិបុលភាព និងបរិយាបន្ន កំណើនសេដ្ឋកិច្ចរបស់ពួកយើងក្នុងរយៈពេល ៥ ទសវត្សរ៍ចុងក្រោយនេះ មានភាពធន់ដែលធ្វើឱ្យអាស៊ានជាតំបន់ដែលមានសេដ្ឋកិច្ចធំជាងគេទី៥ នៅលើពិភពលោក។ ពួកយើងមានសេចក្តីសោមនស្សរីករាយដែលសុខុមាលភាព និងជំនាញរបស់កម្មករនិយោជិតក្នុងអាស៊ានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ និងប្តេជ្ញាថែរក្សានូវវឌ្ឍនភាពនេះ អំឡុងពេលប្រែប្រួលពិភពនៃការងារ។ ពួកយើងបានបញ្ជាក់ជាថ្មីនូវស្មារតីរួម ក្នុងការពង្រឹងភាពធន់ និងការលើកកម្ពស់នវានុវត្តន៍ ដែលជួយរដ្ឋសមាជិកអាស៊ានក្នុងការស្វែងរក និងគ្រប់គ្រងផលប៉ះពាល់នៃការវិវត្តបច្ចេកវិទ្យា ឌីជីថលភាវូបនីយកម្ម និងសេដ្ឋកិច្ចបៃតង ការផ្លាស់ប្តូរប្រជាសាស្ត្រ ការធ្វើទេសន្តរប្រវេសន៍ការងារ និងខ្សែច្រវាក់ផ្គត់ផ្គង់សកល នៅលើទីផ្សារការងាររបស់យើង។ យើងបានឯកភាពជម្រុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធក្នុងចំណោមប្រទេសអាស៊ានបូកបី ដើម្បីសុខុមាលភាព និងភាពធន់របស់កម្មករនិយោជិតក្នុងអនាគតនៃការងារ។

## ស្ថានភាពនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យការងារជាមួយប្រទេសអាស៊ានបូកបី

៣. ពួកយើងស្វាគមន៍ការគាំទ្រពីប្រទេសបូកបី លើសេចក្ដីថ្លែងការណ៍ទីក្រុងវៀងចន្ទន៍ ស្ដីពីការបម្លាស់ទីការទទួលស្គាល់ និងការអភិវឌ្ឍជំនាញសម្រាប់ពលករទេសន្តរប្រវេសក៍, សេចក្ដីថ្លែងការណ៍អាស៊ានស្ដីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ាន, សេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសក៍នេសាទ, សេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការការពារពលករទេសន្តរប្រវេសក៍ និងសមាជិកគ្រួសារនៅក្នុងស្ថានភាពមានវិបត្តិ។ ពួកយើងបានព្រមព្រៀងគ្នាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធ និងការចែករំលែកចំណេះដឹងក្នុងចំណោមប្រទេសអាស៊ានបូកបី ទាក់ទងនឹងអភិបាលកិច្ច នៃការធ្វើទេសន្តរប្រវេសន៍ការងារក្នុងតំបន់។

៤. ពួកយើងរីករាយនឹងវឌ្ឍនភាពដែលសម្រេចបានក្នុងការលើកកម្ពស់លក្ខខណ្ឌមុខរបរ និងការងារក៏ដូចជាកំណើនសេដ្ឋកិច្ច បន្ទាប់ពីជំងឺរាតត្បាតកូវីដ-១៩។ ពួកយើងបានផ្ដល់ការគាំទ្រដល់វឌ្ឍនភាពនៃការអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងភាពធន់ និងភាពហ៊ើសហ្វួនរបស់កម្មករនយោជិតសម្រាប់អនាគតនៃការងារ។ ពួកយើងស្វាគមន៍ចំពោះការបន្តកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ប្រទេសបូកបីក្នុងការរៀបចំកម្លាំងពលកម្មរបស់ពួកយើងសម្រាប់ពេលអនាគត។

៥. ពួកយើងបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីលើការងារឆ្ពោះទៅរកគោលដៅរយៈពេលវែងនៃសមាហរណកម្មក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅជាមួយអាស៊ានជាកម្លាំងជម្រុញ។ ពួកយើងបានកត់សម្គាល់ដោយការពេញចិត្តនូវវឌ្ឍនភាពនៅក្នុងកិច្ចប្រជុំឧត្តមមន្ត្រីការងារបូកបី (SLOM+3) ផែនការការងារសម្រាប់ឆ្នាំ២០២១-២០២៥ និងការរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ Blueprint សម្រាប់សហគមន៍សង្គម-វប្បធម៌អាស៊ានសម្រាប់ឆ្នាំ២០២៥ ផែនការមេ ស្ដីពីការតភ្ជាប់អាស៊ាន (MPAC) ឆ្នាំ២០២៥ និងគំនិតផ្ដួចផ្ដើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) និងផែនការការងារទី៤ សម្រាប់ឆ្នាំ២០២១-២០២៥។

៦. យើងសូមកោតសរសើរចំពោះការគាំទ្ររបស់ប្រជាមានិតចិនក្នុងការអនុវត្តគម្រោង ILO-China ស្ដីពីការពង្រឹងការអភិវឌ្ឍជំនាញនៅកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា តាមរយៈកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ ព្រមទាំងគម្រោងលើកកម្ពស់គំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍សកលដោយផ្ដោតការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការត្បូង-ត្បូងលើវិស័យមុខរបរ និងការងារក្នុងអាស៊ាន (ProSSCE-ASEAN)។ យើងបានកត់សម្គាល់ពីភាពជោគជ័យនៃការរៀបចំសិក្ខាសាលា ស្ដីពីការលើកកម្ពស់មុខរបរ និងការងារប្រកបដោយគុណភាពខ្ពស់ នៅថ្ងៃទី១៩-២០

ខែតុលា ឆ្នាំ២០២៣ នៅទីក្រុងប៉េកាំង វេទិកាចិន-អាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍធនធានមនុស្ស និងពិព័រណ៍ចិន-អាស៊ាន ស្តីពីសេវាកម្មធនធានមនុស្ស នៅថ្ងៃទី៣-៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងណាននីង វេទិកាអាស៊ាន-ចិន ស្តីពីកិច្ចសហប្រតិបត្តិការសុវត្ថិភាពការងារ នៅថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងណាន សិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីការលើកកម្ពស់ជំនាញ និងការងារសមរម្យក្នុងការអភិវឌ្ឍជនបទ នៅថ្ងៃទី២១-២២ ខែឧសភា ឆ្នាំ២០២៤ នៅ Huzhou និងការបណ្តុះបណ្តាលសមត្ថភាព ស្តីពីការអភិវឌ្ឍសុវត្ថិភាពទីក្រុងក្រោមកម្មវិធីកសាងសមត្ថភាពអាស៊ាន-ចិន ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ឆ្នាំ២០២៤ នៅថ្ងៃទី២០-២៦ ខែតុលា ឆ្នាំ២០២៤ នៅខេត្ត Zhejiang ។

៧. ពួកយើងអរគុណចំពោះការគាំទ្ររបស់ប្រទេសជប៉ុនមកលើគម្រោងរបស់អាស៊ានជាច្រើន រួមមាន "ការពង្រីកការអនុវត្តគោលការណ៍ណែនាំអាស៊ានសម្រាប់ការពង្រឹងការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធបញ្ជាក់សមត្ថភាព" ដែលជាគម្រោងក្រោមមូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន ព្រមទាំងការរួមចំណែកផ្សេងៗតាមរយៈអង្គការអន្តរជាតិខាងការងារ (ILO) ឬកិច្ចសហប្រតិបត្តិការបច្ចេកទេសពហុភាគីរវាងជប៉ុន និងរដ្ឋសមាជិកអាស៊ាន និងជំនួយបច្ចេកទេសរបស់អង្គការ JICA។ ពួកយើងបានកត់សម្គាល់នូវភាពជោគជ័យនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន-ជប៉ុនប្រចាំឆ្នាំ ស្តីពីសង្គមប្រកបដោយការថែទាំនៅថ្ងៃទី៩-១០ ខែមីនា ឆ្នាំ២០២៣ ក្រោមមូលបទ "យុគសម័យនៃជីវិត ១០០ឆ្នាំ, ឈានទៅរកការរស់នៅតាមជីវិតពិតរបស់អ្នក" និងនៅថ្ងៃទី២៨-៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុង Oita ក្រោមមូលបទ "ឆ្ពោះទៅរកការកសាងសង្គមមួយដែលមនុស្សគ្រប់គ្នាអាចរស់នៅយ៉ាងរស់រវើក ក្នុងនាមជាខ្លួនឯងនៅក្នុងសហគមន៍"។ ពួកយើងក៏ទន្ទឹងរង់ចាំកិច្ចប្រជុំលើកទី២២ នៅថ្ងៃទី២៥-២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅទីក្រុង Kawasaki ក្រោមមូលបទ "វដ្តប្រកបដោយគុណធម៌នៃការសម្រេចបាននូវការថែទាំសុខភាពជាសកល និងការលើកកម្ពស់សង្គមដែលមានសុខភាពល្អ"។

៨. ពួកយើងអរគុណចំពោះការគាំទ្ររបស់សាធារណរដ្ឋកូរ៉េមកលើគំនិតផ្តួចផ្តើមអាស៊ានជាច្រើន រួមមានការសិក្សា ស្តីពីការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងធនធានមនុស្សអាស៊ាន តាមរយៈការឆ្លើយតបរបស់កម្មវិធីសិក្សា TVET ដែលគាំទ្រដោយឧស្សាហកម្ម និងទីផ្សារព័ត៌មានការងារ និងសហគមន៍សង្គមវប្បធម៌អាស៊ាន (ASCC) វេទិកាស្រាវជ្រាវ និងអភិវឌ្ឍ៖ អនាគតនៃការងារ និងអនាគតនៃការអប់រំ។ ពួកយើងបានសង្កេតឃើញការអនុវត្តជោគជ័យ នៃកម្មវិធីបម្លាស់ទី TVET របស់អាស៊ាន-សាធារណរដ្ឋកូរ៉េ ដោយក្រុមទី១ បានបញ្ចប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ និងក្រុមទី២ និងទី៣ បន្តពីខែមេសា ដល់ ខែវិច្ឆិកា ឆ្នាំ២០២៤ និងបន្តដល់សិក្ខាសាលាចុងក្រោយនៅថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០២៤។ ពួកយើងបានកត់សម្គាល់នូវភាពជោគជ័យ នៃសិក្ខាសាលាចែករំលែកគោលនយោបាយកូរ៉េខាងត្បូង-អាស៊ានប្រចាំឆ្នាំ ក្នុងវិស័យមុខរបរ និងការងារ នៅថ្ងៃទី១-២ ខែធ្នូ

ឆ្នាំ២០២២ ក្រោមមូលបទ "ការចែករំលែកនូវការផ្លាស់ប្តូរគោលនយោបាយមុខរបរ និងការងារដោយសារបដិវត្តន៍ឧស្សាហកម្មលើកទី៤ (4IR) និងឌីជីថលនីយកម្ម" នៅថ្ងៃទី៣០ ខែវិច្ឆិកាដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ក្រោមមូលបទ "ទស្សនវិស័យការងារអាស៊ាន និងនិន្នាការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងយុគសម័យឌីជីថល" និងនៅថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ ក្រោមមូលបទ "ការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាសាស្ត្រ និងពិភពនៃការងារប្រកបដោយនិរន្តរភាព"។ យើងក៏បានកត់សម្គាល់ផងដែរ អំពីការប្រព្រឹត្តិទៅនៃវេទិកាអភិវឌ្ឍធនធានមនុស្សអាស៊ាន+៣(HRD) ប្រចាំឆ្នាំ នៅថ្ងៃទី១០-១១ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមមូលបទ "ការអភិវឌ្ឍជំនាញឌីជីថល និង TVET សម្រាប់កំណើនបៃតង ភាពធន់ និងបរិយាបន្ន" និងនៅថ្ងៃទី២-៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមមូលបទ "បរិវត្តឌីជីថលសម្រាប់នវានុវត្តន៍ធនធានមនុស្ស" ។ ពួកយើងក៏ទន្ទឹងរង់ចាំភាពជោគជ័យនៃវេទិកាមួយទៀតនៅថ្ងៃទី៧-៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រោមមូលបទ "ការពង្រឹងកម្លាំងពលកម្មសម្រាប់អនាគតប្រកបដោយនិរន្តរភាព និងបរិយាបន្ន"។

៩. យើងទន្ទឹងរង់ចាំការបញ្ចប់ទាន់ពេលវេលានៃផែនការការងារ SLOM+3 ឆ្នាំ២០២១-២០២៥ តាមរយៈសកម្មភាពដែលបានគ្រោងទុក នៅលើប្រព័ន្ធផ្លាស់ប្តូរជំនាញសម្រាប់អនាគតនៃការងារ ការលើកកម្ពស់ការងារសមរម្យនៅតំបន់ជនបទ ភាពជាអ្នកដឹកនាំក្នុងត្រីភាគី និងបរិយាបន្ននៃការងារសម្រាប់ជនមានពិការភាព។ យើងបានយល់ព្រមនូវការសហការយ៉ាងជិតស្និទ្ធ ក្នុងការបង្កើតផែនការការងារ SLOM+3 ឆ្នាំ២០២៦-២០៣០ ដែលប្រកបដោយបរិយាបន្ន ដោយមិនកំណត់ត្រឹមការលើកកម្ពស់សហគ្រិនភាព និងមុខរបរប្រកបដោយនិរន្តរភាព ការអភិវឌ្ឍធនធានមនុស្សទាំងជំនាញបៃតង និងឌីជីថល សន្តិសុខសង្គម និងសុវត្ថិភាព និងសុខភាពនៃការងារ គឺរួមបញ្ចូលទាំងវិស័យដែលពិបាកទៅដល់ ជាពិសេសពលករទេសន្តរប្រវេសក៍នេសាទក្នុងតំបន់។

១០. យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃប្រទេសសិង្ហបុរី ជាពិសេសក្រសួងហត្ថពលកម្មចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងការរៀបចំដ៏ល្អឥតខ្ចោះលើកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានបូកបីលើកទី១៣ (13th ALMM+3)។ យើងក៏បានថ្លែងអំណរគុណដល់លេខាធិការដ្ឋានអាស៊ានសម្រាប់ការគាំទ្រឥតឈប់ឈររបស់ខ្លួនក្នុងការរៀបចំសម្រាប់កិច្ចប្រជុំ និងអំឡុងពេលនៃកិច្ចប្រជុំនេះ។

១១. យើងបានយល់ព្រមជួបគ្នាម្តងទៀត នៅឆ្នាំ២០២៦ ក្រោមអាណត្តិជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានរបស់ប្រទេសថៃ។

---